# ច្បាប់
# ស្តីពីការធ្វើ
# បាតុកម្មដោយ
# សន្តិវិធី

# ច្បាប់

# ស្តីពី

# ការធ្វើបាតុកម្មដោយសន្តិវិធី

# ព្រះរាជក្រម

នស/រកម/១២០៩/០១៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

E du CAMBODGE

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការធ្វើបាតុកម្មដោយសន្តិវិធី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណង ធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនត្រូវឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និង កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តលើរាល់ការប្រមូលផ្តុំគ្នា ឬ ការដង្ហែក្បួនធ្វើបាតុកម្មដោយសន្តិវិធី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមិនអនុវត្តចំពោះ :

១-ការជួបប្រជុំ ឬ ការប្រមូលផ្តុំគ្នា ឬ ការហែក្បួនក្នុងយុទ្ធនាការឃោសនាបោះឆ្នោតណាមួយ ។

២-ការប្រមូលផ្តុំគ្នាខាងក្នុង និង ខាងក្រៅអែបប្របរបងរោងចក្រ ឬ សហគ្រាស ឬ ស្ថាប័ននានា ពាក់ព័ន្ធនឹងវិវាទការងារ ដែលត្រូវដាក់បញ្ចូលក្នុងដែនអនុវត្តនៃច្បាប់ការងារ ។

៣-ការដើរហែក្បួនលុហយាត្រា ដើរហែសព និងការប្រមូលផ្តុំគ្នាដទៃទៀត ក្នុងគោលបំណងបម្រើសាសនា សិល្បៈ វប្បធម៌ ទំនៀមទម្លាប់ប្រពៃណីជាតិ និងសកម្មភាពផ្សព្វផ្សាយអប់រំ ដើម្បីផលប្រយោជន៍សង្គម ។

**មាត្រា ៤.-**

បាតុកម្មដោយសន្តិវិធី សំដៅលើការប្រមូលផ្តុំគ្នា ឬ ការដង្ហែក្បួន ដោយមនុស្សមួយក្រុម ដើម្បីទាមទារ តវ៉ា ឬ សម្តែងជាសាធារណៈនូវមនោសញ្ចេតនា គំនិត ឬ ឆន្ទៈរបស់ខ្លួនចំពោះស្ថានភាព ឬ មនោគមវិជ្ជានយោបាយផ្សេងៗដោយសន្តិវិធី ។

## ជំពូកទី ២
## នីតិវិធីនៃការជូនដំណឹងអំពីការធ្វើបាតុកម្មដោយសន្តិវិធី

**មាត្រា ៥.–**

ក្រុមបុគ្គលណា ដែលមានបំណងរៀបចំធ្វើបាតុកម្មដោយសន្តិវិធី នៅទីកន្លែងសាធារណៈណាមួយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងទីកន្លែងនោះ ។

**មាត្រា ៦.–**

លិខិតជូនដំណឹងនោះត្រូវបញ្ជាក់អំពី :

-នាមត្រកូល នាមខ្លួន និង អាសយដ្ឋានអចិន្ត្រៃយ៍ សម្រាប់ទំនាក់ទំនងរបស់អ្នកដឹកនាំចំនួនបី (៣)នាក់ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងផង

-គោលបំណងនៃការធ្វើបាតុកម្មដោយសន្តិវិធី

-កាលបរិច្ឆេទ ពេលវេលា និង រយៈពេល នៃការធ្វើបាតុកម្មដោយសន្តិវិធី ទីកន្លែង និង ផ្លូវដែលត្រូវប្រើប្រាស់សម្រាប់សកម្មភាព ចំនួនអ្នកចូលរួម ព្រមទាំងចំនួនយានជំនិះតាមប្រភេទនីមួយៗ ។

អ្នកដាក់លិខិតជូនដំណឹងទាំងអស់ត្រូវធានាថាគោរព ហើយអនុវត្តតាមតួនាទី និង ភារកិច្ចទទួលខុសត្រូវ ដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ។

**មាត្រា ៧.–**

លិខិតជូនដំណឹងត្រូវដាក់នៅសាលារាជធានី ឬ សាលាខេត្ត យ៉ាងហោចណាស់ប្រាំ(៥)ថ្ងៃ នៃថ្ងៃធ្វើការងារមុនពេលកំណត់ នៃការធ្វើបាតុកម្មដោយសន្តិវិធី ។

**មាត្រា ៨.–**

នៅពេលបានទទួលលិខិតជូនដំណឹងហើយ សាលារាជធានី ឬ សាលាខេត្ត :

១-ត្រូវចេញបង្កាន់ដៃទទួលស្គាល់ជាលាយលក្ខណ៍អក្សរ ជូនអ្នកដែលបាន ដាក់លិខិតជូនដំណឹង ។

២-ត្រូវផ្សព្វផ្សាយលិខិតជូនដំណឹងនេះជាបន្ទាន់ នៅទីកន្លែងណាមួយ ដែល ងាយមើលឃើញ នៅក្នុងអគាររដ្ឋបាល ឬ នៅក្នុងគេហទំព័រផ្លូវការរបស់ខ្លួន ។

៣-ត្រូវបញ្ជូនច្បាប់ថតចម្លងនៃលិខិតជូនដំណឹងនេះ ទៅស្នាក់ការនគរបាល មូលដ្ឋាន ស្នាក់ការកងរាជអាវុធហត្ថ និង អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានការ ពាក់ព័ន្ធនឹងទីកន្លែងធ្វើបាតុកម្មនោះ ។

**មាត្រា ៩.–**

អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមាន ចំពោះលិខិត ជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែ :

-ការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើន ព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណី ជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ ។

-មានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណា មួយ ឬ នឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ១០.–**

អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ចត្រូវពិនិត្យ និង ធ្វើការឆ្លើយតបវិញក្នុង រយៈពេលយ៉ាងយូរត្រឹមបី(៣)ថ្ងៃ នៃថ្ងៃការងារ ដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹង ត្រូវបានគេដាក់ជូន ។ ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច ខកខានមិន បានឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី មានន័យថា អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច បានព្រមព្រៀងហើយ ។

**មាត្រា ១១.–**

ក្នុងករណីដែលអាជ្ញាធរដែនដីរាជធានី ឬ ខេត្ត មានសមត្ថកិច្ច មានព័ត៌មានច្បាស់ថា

ការធ្វើបាតុកម្មនេះ នឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬ នឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរដែនដីរាជធានី ឬ ខេត្ត ត្រូវធ្វើការឆ្លើយតប ដោយជូនដំណឹងជាបន្ទាន់ទៅអ្នកដែលបានដាក់លិខិតជូនដំណឹង ដើម្បីឱ្យពួកគេអាចមាន ពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ធ្វើការពិចារណាដើម្បី ពិភាក្សាគ្នាដោះស្រាយ ។

**មាត្រា ១២.-**

ក្រោយពីបានពិភាក្សាគ្នាហើយ បើភាគីទាំងពីរនៅតែមិនព្រមព្រៀងគ្នាទៀតនោះ អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ច ត្រូវស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និង ត្រូវ ផ្តល់ជូនដល់ម្ចាស់លិខិតជូនដំណឹងវិញ ក្នុងរយៈពេលយ៉ាងយូរម្ភៃបួន(២៤)ម៉ោង មុនពេល កំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី ។ ឯកសារថតចម្លងនៃការសម្រេច រួមទាំងព័ត៌មាន លំអិត នៃការកែប្រែដែលបានព្រមព្រៀងគ្នា ត្រូវផ្តល់ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងជូនទៅអាជ្ញាធរដទៃទៀត ដែលមានតំបន់អាចនឹងទទួលរងនូវការប៉ះពាល់ ដោយសារ ការធ្វើបាតុកម្មដោយសន្តិវិធីនេះ ។

**មាត្រា ១៤.-**

មិនតម្រូវឱ្យមានការបញ្ជាក់ និងធានាសព្វគ្រប់ដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌទី ១ នៃច្បាប់នេះទេ ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរមានចុះហត្ថលេខា ឬ ស្នាម មេដៃ និងភ្ជាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង របស់អ្នកដឹកនាំធ្វើបាតុកម្មដោយ សន្តិវិធី ចំនួនបី(៣)នាក់ ដល់អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ចនៅមូលដ្ឋាន នោះ យ៉ាងហោចណាស់ឱ្យបានមុនដប់ពីរ(១២)ម៉ោងក្នុងថ្ងៃការងារ ឬ មុនសាមសិបប្រាំ មួយ(៣៦)ម៉ោងក្នុងថ្ងៃឈប់សម្រាក ប្រសិនបើការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានគេធ្វើ ឡើងនៅតាមទីកន្លែងដូចខាងក្រោម :

7/12

១-នៅកន្លែងបញ្ចេញមតិជាសាធារណៈ ដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវតាមច្បាប់ ឬ តាមបទបញ្ជា ហើយដែលការធ្វើបាតុកម្មដោយសន្តិវិធីនោះ មានមនុស្សចូលរួមយ៉ាងច្រើនបំផុតត្រឹមពីររយ (២០០) នាក់ សម្រាប់រាជធានី ឬ ខេត្តនីមួយៗ ឬ

២-នៅកន្លែងដែលជាទ្រព្យសម្បត្តិឯកជន ឬ ជាទ្រព្យសម្បត្តិសមូហភាព ក្នុងករណីមានការយល់ព្រមពីម្ចាស់ទ្រព្យ ឬ ពីគណៈគ្រប់គ្រង ដែលជាអ្នកមើលការខុសត្រូវលើទ្រព្យសម្បត្តិសមូហភាពនោះ ហើយការធ្វើបាតុកម្មដោយសន្តិវិធីមានមនុស្សចូលរួមយ៉ាងច្រើនបំផុតត្រឹមពីររយ (២០០) នាក់ ។

ប៉ុន្តែ ក្នុងករណីដែលចំនួនក្រុមនៃការធ្វើបាតុកម្មដោយសន្តិវិធី មានចាប់ពី ពីរ(២) ក្រុមផ្សេងគ្នាឡើងទៅ ហើយចង់ធ្វើនៅកន្លែងតែមួយ និង ពេលវេលាតែមួយនោះ អាជ្ញាធរដែនដីរាជធានី ឬ ខេត្តមានសមត្ថកិច្ចត្រូវសម្រេចឱ្យក្រុមអ្នកដែលបានដាក់សេចក្តីជូនដំណឹងមុនទទួលបានសិទ្ធិធ្វើមុន ឬ អាចអនុញ្ញាតឱ្យធ្វើនៅកន្លែងមួយផ្សេងទៀត ដែលមានចម្ងាយយ៉ាងតិច ប្រាំរយ(៥០០)ម៉ែត្រ ។

ការធ្វើបាតុកម្មដោយសន្តិវិធី ដូចមានចែងក្នុងមាត្រានេះ អាចប្រព្រឹត្តទៅបាន តែក្នុងចន្លោះពេលពីម៉ោងប្រាំមួយ(៦)ព្រឹក ដល់ម៉ោងប្រាំមួយ(៦)ល្ងាចប៉ុណ្ណោះ ។

## ជំពូកទី ៣
## ការទទួលខុសត្រូវរបស់
## អ្នកដឹកនាំធ្វើបាតុកម្ម និង អាជ្ញាធរមានសមត្ថកិច្ច

**មាត្រា ១៥.–**

ការធ្វើបាតុកម្មដោយសន្តិវិធី ដែលបានទទួលការព្រមព្រៀង មានការហែក្បួនលើផ្លូវសាធារណៈ អាជ្ញាធរដែនដីឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត រាជធានី ឬ មន្ត្រីដែលត្រូវបានចាត់តាំងជាតំណាង ត្រូវសហការជាមួយនគរបាលមូលដ្ឋាន និង កងរាជអាវុធហត្ថ ដើម្បីទប់ស្កាត់ផលអាក្រក់ដែលនឹងអាចកើតមាន ដោយធ្វើការកំណត់ផ្លូវខាងលើឱ្យមានភាពងាយស្រួល និង សម្រួលចរាចរណ៍សម្រាប់យានយន្ត ដើម្បីកុំឱ្យមានការរំខានដល់ដំណើរការរបស់ជីវភាព អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឬ ជំនួញផ្សេងៗ ។

**មាត្រា ១៦.-**

អ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី ត្រូវទទួលខុសត្រូវក្នុងការចាត់វិធានការសមស្រ ដើម្បីរក្សាឱ្យបានថា ការធ្វើបាតុកម្មនេះ នឹងប្រព្រឹត្តទៅដោយសន្តិវិធី និង តាមលក្ខខណ្ ដូចខាងក្រោម :

១-ជូនដំណឹងដល់អ្នកចូលរួមអំពីការទទួលខុសត្រូវរបស់ខ្លួន ដូចមាន ចែងក្នុងចំណុចទី ៣ នៃមាត្រានេះ ។

២-ពិភាក្សា និង សហការជាមួយមន្ត្រីមូលដ្ឋាន និង អាជ្ញាធរមានសមត្ថ-កិច្ចដែលពាក់ព័ន្ធ ដើម្បីធានាឱ្យការធ្វើបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធី ។

៣-រក្សាសណ្តាប់ធ្នាប់របៀបរៀបរយឱ្យបានល្អ និង ត្រឹមត្រូវតាមពេលវេល និង ទីកន្លែងកំណត់ គិតពីការចាប់ផ្តើមរហូតដល់ការបញ្ចប់ទៅវិញ នៃការធ្វើបាតុកម្មដោ សន្តិវិធី ។

**មាត្រា ១៧.-**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការការពារដល់ក្បួនបាតុកម្មដោយសន្តិវ ដើម្បីធានារក្សាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អប្រសើរ ហើ មិនត្រូវជ្រៀតជ្រែកដល់ការប្រព្រឹត្តទៅ នៃការធ្វើបាតុកម្មដោយសន្តិវិធីឡើយ ។

**មាត្រា ១៨.-**

នៅពេលមានការស្នើសុំជំនួយពីអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរមាន សមត្ថកិច្ច ត្រូវខិតខំឆ្លើយតបដោយយកចិត្តទុកដាក់នូវសំណូមពរសមស្រប ដោយផ្អែកល មូលដ្ឋានច្បាប់ ដើម្បីធានាដល់ការអនុវត្តសិទ្ធិសេរីភាពធ្វើបាតុកម្មដោយសន្តិវិធី និង ក ប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈប្រកបដោយភាពថ្លៃថ្នូរ ។

**មាត្រា ១៩.-**

អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវបានចាត់តាំងឱ្យរក្សាសន្តិសុខ សុវត្ថិភា សណ្តាប់ធ្នាប់សាធារណៈ នៅកន្លែងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវស្លៀកពាក់ឯកសណ្ឋា ឱ្យបានត្រឹមត្រូវ ព្រមទាំងមានស្លាកឈ្មោះ និង អត្តលេខសម្គាល់ខ្លួន បង្ហាញនៅផ្ទៃ ទ្រូងខ្លួន និង ត្រូវប្រកាន់ខ្ជាប់នូវអត្តចរិតអត់ធ្មត់ដាច់ខាត ។

LE MINISTERE DU PALAIS ROYAL

**មាត្រា ២០.-**

ការធ្វើបាតុកម្មដោយសន្តិវិធី ដែលមានការព្រមព្រៀង រាប់ទាំងការព្រមព្រៀង ដោយអាជ្ញាធរដែនដីរាជធានី ឬ ខេត្តមិនបានឆ្លើយតបដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះផង មិនត្រូវបានបំបែកទេ ។

ក្នុងករណីបាតុកម្មដោយសន្តិវិធី បានក្លាយជាអំពើហិង្សា អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ និង បញ្ឈប់បាតុកម្មនេះជាបន្ទាន់ ។

ទោះបីជាបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធីក៏ដោយ ប៉ុន្តែបើមិនបានដាក់លិខិតជូនដំណឹងស្របតាមមាត្រា ៥ មាត្រា ៦ និង មាត្រា ១៤ នៃច្បាប់នេះ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់វិធានការបញ្ឈប់បាតុកម្មនេះបាន ។

## ជំពូកទី ៤
## នីតិវិធីដោះស្រាយបទល្មើស និង ទោសប្បញ្ញត្តិ

**មាត្រា ២១.-**

ត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធី ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ មាត្រា ១៦ និង មាត្រា ២០ កថាខណ្ឌទី ២ និង ទី ៣ នៃច្បាប់នេះ ។

**មាត្រា ២២.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះមន្ត្រីអាជ្ញាធរដែនដី ឬ មន្ត្រីអាជ្ញាធរមានសមត្ថកិច្ចណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ និង មាត្រា ២០ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃច្បាប់នេះ ។

**មាត្រា ២៣.-**

ក្នុងករណីបាតុករណាមានកាន់ឧបករណ៍ ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ឬ អាចបង្កទុក្ខទោសដល់អ្នកដទៃ ឬ ប្រព្រឹត្តអំពើណាមួយដែលជាការរំលោភសិទ្ធិសេរីភាពអ្នកដទៃ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតឧបករណ៍ទាំងនោះចេញ ឬ ហាមប្រាមកុំឱ្យបាតុករនោះប្រព្រឹត្តអំពើនេះទៀត ។ ប្រសិនបើជននោះមានការរឹងរូសមិនព្រមប្រគល់

ឱ្យ ឬ មិនព្រមឈប់ប្រព្រឹត្តអំពើនេះ សមត្ថកិច្ចត្រូវធ្វើការឃាត់ខ្លួនជាបណ្តោះអាសន្នរហូតដល់បាតុកម្មដោយសន្តិវិធីត្រូវបានបញ្ចប់សព្វគ្រប់ ទើបធ្វើការដោះលែងវិញ លើកលែងតែមានបទល្មើសអ្វីផ្សេងទៀត ។

**មាត្រា ២៤.-**

ក្នុងករណីបាតុករណាមានកាន់អាវុធ ឬ ជាតិផ្ទុះ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតអាវុធ ឬ ជាតិផ្ទុះទាំងនោះ និងធ្វើការឃាត់ខ្លួន រួចហើយបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់ជាធរមាន ។

**មាត្រា ២៥.-**

ជនណាឆ្លៀតឱកាសក្នុងពេលធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីប្រព្រឹត្តអំពើលួច ប្លន់ ឬ បណ្តាលឱ្យអន្តរាយទ្រព្យសម្បត្តិឯកជន ឬ ទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ២៦.-**

ប្រសិនបើដំណើរការនៃការធ្វើបាតុកម្មដោយសន្តិវិធីបង្កជាអំពើហិង្សាបណ្តាលឱ្យអន្តរាយដល់ទ្រព្យសម្បត្តិឯកជនក្តី ឬ ទ្រព្យសម្បត្តិសាធារណៈក្តី ការជួសជុលការខូចខាតត្រូវជាបន្ទុករបស់ជនល្មើស និង អ្នកសមគំនិត ។

ក្នុងករណីអ្នកទាំងនោះមិនមានលទ្ធភាពធ្វើការជួសជុលការខូចខាត អាជ្ញាធរមានសមត្ថកិច្ចត្រូវបង្កសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ២៧.-**

បើដំណើរការនៃការធ្វើបាតុកម្មដោយសន្តិវិធី បង្កជាអំពើហិង្សា ជនណាដែលបានប្រព្រឹត្តល្មើសបណ្តាលឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬ បាតុករ ឬ បុគ្គលដទៃទៀត មានរបួសស្នាម ឬ បណ្តាលឱ្យស្លាប់ ជននោះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។



## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា ២៨.–**

ក្នុងរយៈពេលប្រាំមួយ(៦)ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន រាជធានី និង ខេត្តនីមួយៗត្រូវបង្កើត "កន្លែងបញ្ចេញមតិជាសាធារណៈ" ដោយត្រូវជ្រើសរើសទីធ្លា ឬ មណ្ឌលសមស្របមួយកន្លែងដែលមនុស្សទូទៅងាយស្តាប់ឮ និង មើលឃើញ នៅក្នុងទឹកដីនៃដែនសមត្ថកិច្ចរបស់ខ្លួន សម្រាប់ធ្វើបាតុកម្មដោយសន្តិវិធី ឬ បញ្ចេញមតិជាសាធារណៈ ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ២៩.–**

ច្បាប់ស្តីពីបាតុកម្ម ដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ១១៩ក្រ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩១ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នស/រកម.០៩១២.១១៥៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ:១០៦៧ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ចិនកេន

12/12